**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣ ❀ ៤៤

**ក្រសួងធនធានទឹក និងឧតុនិយម**

លេខ ១៤៨ សជណ.ធទឧ

## សេចក្តីជូនដំណឹង
## ស្តីពីស្ថានភាពទឹកជំនន់ទន្លេមេគង្គ

បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកទន្លេមេគង្គ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ឥទ្ធិពលរបស់ជ្រលងសម្ពាធទាប នឹងបង្កឱ្យមានភ្លៀងធ្លាក់ច្រើនជាបន្តបន្ទាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសនៅអាងទន្លេមេគង្គ ក្នុងប្រទេសថៃ និងឡាវ ។

ស្ថានភាពបែបនេះ នឹងបណ្តាលឱ្យកំពស់ទឹកទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប និងកំពស់ទឹកបឹងទន្លេសាប ចាប់ផ្តើមហក់ឡើងជាបន្តបន្ទាប់ ក្នុងកំឡុងពេលពី 4 ទៅ 6 ថ្ងៃខាងមុខ ។ ទឹកអាចនឹងហូរចូលទៅតំបន់ទំនាបមួយចំនួនដែលស្ថិតនៅតាមដងទន្លេ ធ្វើឱ្យលិច និងប៉ះពាល់ដល់ដំណាំកសិផលរបស់ប្រជាពលរដ្ឋនៅតំបន់ទាំងនោះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអាជ្ញាធរដែនដី និងប្រជាពលរដ្ឋ ដែលរស់នៅតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ រួសរាន់មានវិធានការណ៍ប្រមូលកសិផលឱ្យបានទាន់ពេលវេលា ។ ម្យ៉ាងវិញទៀត បើទោះជាកំពស់ទឹកទន្លេនៅពេលនេះមិនទាន់កើនឡើងខ្ពស់ខ្លាំងក្តី ប៉ុន្តែចរន្ត និងល្បឿនរបស់ទឹក ចាប់ផ្តើមប្រែប្រួល ។ ដូចនេះ សូមសាធារណជន និងអ្នកធ្វើដំណើរតាមដងទន្លេ បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្ន ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។/

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៤
**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh